មគ្គុទ្ទេសក៍ប្រើប្រាស់

# និមិត្តសញ្ញាសម្គាល់

របស់បេឡាជាតិសន្តិសុខសង្គម

# និមិត្តសញ្ញាសម្គាល់

## និមិត្តសញ្ញាសម្គាល់នេះមានខ្លឹមសារ និងអត្ថន័យដូចខាងក្រោម៖

- មាន រាង ទាំង មូល រាង មូល ព័ទ្ធដោយ កួរ ស្រូវ រាង ស្នែង ក្របីព ណ៌ទឹក មាស រូប រាង ខាង ក្នុង មាន រូប ម នុស្សប្រុស - ស្រី នៅខាង ក្នុង ក ង ច ក្រ និង គ ម្រប ព ណ៌ទឹក ស មុទ្ររាង ជាពាក់ក ណ្ដាល រ ង្វង់។ នៅលើផ្ទៃគម្របកងចក្រមានសរសេរអក្សរ “**ប.ស.ស.**”និង “**NSSF**”។ ព័ទ្ធជុំវិញកងចក្រមានផ្ដុំតួអក្សររាងជារង្វង់ដាក់ថា “**បេឡាជាតិសន្តិសុខសង្គម**” និង “National Social Security Fund”

- **កួរស្រូវ**ពណ៌ទឹកមាសមាន ៩ថ្នាក់ តំណាងនូវតារាកាលិកទាំងប្រាំបួន ដែលចែងក្នុងបទដ្ឋានអន្តរជាតិស្ដីពីសន្តិសុខសង្គម

- អក្សរ **បេឡាជាតិសន្តិសុខសង្គម** និង **National Social Security Fund** ពណ៌ទឹកសមុទ្ររាងជារង្វង់តំណាងឈ្មោះគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានបេសកកម្មក្នុងការគ្រប់គ្រងនិងចាត់ចែងរបបសន្តិសុខសង្គមសម្រាប់បុគ្គលនៃវិស័យសាធារណៈនិងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះ

- **រូបពាក់កណ្ដាលរង្វង់**គ្របពីលើកងចក្រ ពណ៌ទឹកសមុទ្រ ដែលមានអក្សរ **ប.ស.ស.** និង **NSSF** ពណ៌សតំណាងនូវការការពារហានិភ័យសង្គម ចំពោះបុគ្គលនៃវិស័យសាធារណៈនិងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះ

- **រូបកងចក្ររាងពាក់កណ្ដាលរង្វង់**ពណ៌ទឹកសមុទ្រ តំណាងនូវការចូលរួមនៃវិស័យសាធារណៈ និងវិស័យឯកជន។ រីឯ**កាំកងចក្រ**ចំនួន ១១ តំណាងនូវសមាសភាពក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គមទាំង១១ រូប

- **រូបមនុស្សប្រុស-ស្រី**ស្ថិតនៅខាងក្នុងកងចក្រតំណាងនូវបុគ្គលនៃវិស័យសាធារណៈនិងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះដែលត្រូវទទួលបានការការពារពីរបបសន្តិសុខសង្គមតាមច្បាប់។

## កំណត់សម្គាល់និមិត្តសញ្ញា

☛ ដើម្បីធានាថារូបរាង ឬវិមាត្ររបស់និមិត្តសញ្ញាមិនត្រូវបានផ្លាស់ប្តូរទ្រង់ទ្រាយដើម គ្រប់ការប្រើប្រាស់ត្រូវអនុវត្តតាមគោលការណ៍ដូចបានកំណត់ក្នុងរូបខាងស្តាំដៃនេះ

## ទម្រង់និមិត្តសញ្ញាសម្គាល់

☛ កួរស្រូវរាងស្នែងក្របីពណ៌ទឹកមាស ខាងក្នុងមានមនុស្សប្រុស-ស្រី នៅខាងក្នុងកងចក្រ និងគម្របពណ៌ទឹកសមុទ្ររាងជាពាក់កណ្តាលរង្វង់អក្សរអង់គ្លេសពណ៌ខៀវនៅខាងក្រោម។ និមិត្តសញ្ញាទម្រង់ទី១នេះ ជាទម្រង់ចម្បងផ្លូវការ គប្បីប្រើឱ្យបានច្រើន និងញឹកញាប់តាមការដែលអាចធ្វើទៅបាន។

## បរិវេណស្រឡះ

☛ បរិវេណស្រឡះគឺសំដៅលើបរិវេណដែលនៅជុំវិញនិមិត្តសញ្ញាសម្គាល់ដែលមិនអនុញ្ញាតឱ្យមានធាតុអ្វីផ្សេង តាំងនៅ។ បរិវេណស្រឡះអប្បបរមាត្រូវកំណត់តាមទំហំកម្ពស់អក្សរ “**ស**”។

# ទំហំនិមិត្តសញ្ញាសម្គាល់អប្បបរមា

☛ ទំហំនិមិត្តសញ្ញាសម្គាល់របស់បេឡាជាតិសន្តិ-សុខសង្គម ដែលត្រូវប្រើលើសម្ភារៈផ្សព្វផ្សាយផ្សេងៗ គប្បីមានទំហំដែលតូចបំផុតគឺបណ្តោយមិនតិចជាង ១,៥០ ស.ម សម្រាប់ទម្រង់និមិត្តសញ្ញាសម្គាល់។

1.50 cm

# និមិត្តសញ្ញាដែលអាចប្រើបាន

☛ និមិត្តសញ្ញាគឺមាន ៣ពណ៌ ដូច្នេះគ្រប់សម្ភារៈផ្សព្វផ្សាយគប្បីប្រើនិមិត្តសញ្ញា ដែលមានកួរស្រូវរាងស្នែងក្របីពណ៌ទឹកមាស ខាងក្នុងមានមនុស្សប្រុស-ស្រីនៅខាងក្នុងកងចក្រ និងគម្របពណ៌ទឹកសមុទ្ររាងជាពាក់កណ្តាលរង្វង់អក្សរអង់គ្លេសពណ៌ខៀវនៅខាងក្រោម។ តែកាលៈទេសៈខ្លះ យើងមិនអាចប្រើនិមិត្តសញ្ញាដែលមាន ៣ពណ៌បាន ដូច្នេះហើយមានករណីលើកលែងមួយចំនួនត្រូវបានអនុញ្ញាតឱ្យប្រើ ប៉ុន្តែបើអាចជៀសបានគប្បីកុំប្រើវា។

និមិត្តសញ្ញា ៣ពណ៌

និមិត្តសញ្ញា ៣ពណ៌
ផ្ទៃរាងជារង្វង់ ពណ៌ស

និមិត្តសញ្ញាពណ៌ខៀវ

និមិត្តសញ្ញាពណ៌ទឹកមាស

និមិត្តសញ្ញាពណ៌ស ផ្ទៃពណ៌ខៀវ

## ពណ៌ចម្បង

PATONE 286C
C:100 M:89 Y:9 K:5
R:0 G:51 B:160

PATONE 116C
C:0 M:18 Y:100 K:0
R:255 G:205 B:0

PATONE 2985C
C:52 M:0 Y:0 K:0
R:103 G:211 B:251

## និមិត្តសញ្ញាសម្គាល់ដែលមិនអាចប្រើបាន

☛ ឧទាហរណ៍ខាងក្រោមនេះបង្ហាញពីប្រភេទនិមិត្តសញ្ញាសម្គាល់ ដែលមានរូបរាងមិនត្រឹមត្រូវ ឬប្រើប្រាស់ពណ៌មិនត្រឹមត្រូវ។ ដើម្បីប្រើនិមិត្តសញ្ញាឱ្យបានត្រឹមត្រូវ គប្បីប្រើនិមិត្តសញ្ញា អេឡិចត្រូនិកស្របតាមមគ្គុទ្ទេសក៍។

ហាមបន្ថែមបន្ទាត់នៅជុំវិញ
និមិត្តសញ្ញាឬធាតុណាមួយ
របស់និមិត្តសញ្ញា។

ហាមប្តូរពណ៌លើធាតុផ្សេងៗ
លើកលែងតែមានចែងក្នុង
មគ្គុទ្ទេសក៍នេះ។

ហាមធ្វើឱ្យខូចរាងដើមរបស់និមិត្តសញ្ញា មិនថា
រូបក្ករស្រូវ ឬ មនុស្សប្រុស-ស្រី ឬ កងចក្រ។

ហាមដាក់និមិត្តសញ្ញានៅលើផ្ទៃទាំងឡាយ
ដែលមិនធ្វើឱ្យនិមិត្តសញ្ញាមានភាពលេចធ្លោ។

## ទីតាំងល្អរបស់និមិត្តសញ្ញាសម្គាល់

☛ ដើម្បីទទួលបានការទាក់ភ្នែក និមិត្តសញ្ញាសម្គាល់គួរមានទីតាំងដូចមាននៅក្នុងឧទាហរណ៍នេះ។









# ទីតាំងល្អរបស់និមិត្តសញ្ញាសម្គាល់




ដាក់ចំកណ្តាលស្គ្រីន សម្រាប់ផ្ទាំងវីដេអូចុងក្រោយ



ដាក់និមិត្តសញ្ញានៅលើរូបភាពវីដេអូ គប្បីដាក់នៅផ្នែកស្តាំខាងលើ កម្រិតច្បាស់ ៨០%។




ដាក់ចំកណ្តាលស្គ្រីន សម្រាប់ផ្ទាំងវីដេអូចុងក្រោយ




ដាក់ចំកណ្តាលស្គ្រីន សម្រាប់ផ្ទាំងវីដេអូចុងក្រោយ

# ការប្រើជាមួយនិមិត្តសញ្ញាសម្គាល់ដទៃទៀត

☛ ការប្រើនិមិត្តសញ្ញាសម្គាល់បេឡាជាតិសន្តិសុខសង្គម ជាមួយនិមិត្តសញ្ញាសម្គាល់ដ៏ទៃទៀត គួរតែមានកម្ពស់ស្មើគ្នា ឬទាបបំផុតកម្ពស់ក៏ ៧០% នៃនិមិត្តសញ្ញាសម្គាល់ដទៃទៀតដែរ។ តាមគោលការណ៍បរិវេណស្រឡះគប្បីអនុវត្តដើម្បីឱ្យនិមិត្តសញ្ញាសម្គាល់មានភាពលេចធ្លោ និងអាចមើលស្គាល់។

កម្ពស់អប្បបរមាមិនគួរទាបជាង ៧០% នៃកម្ពស់និមិត្តសញ្ញាដែលខ្ពស់ជាងគេនោះទេ។

កម្ពស់អប្បបរមាមិនគួរទាបជាង ៧០% នៃកម្ពស់និមិត្តសញ្ញាសម្គាល់ដែលខ្ពស់ជាងគេនោះទេ។




កម្ពស់អប្បបរមាមិនគួរទាបជាង ៧០% នៃកម្ពស់និមិត្តសញ្ញាសម្គាល់អង្គភាពដៃគូរនោះទេ។



# សេវាផ្តល់ព័ត៌មាន

# ១២៨៦

២៤ម៉ោង / ៧ថ្ងៃ

បណ្តាញសង្គមបេឡាជាតិសន្តិសុខសង្គម